# ឯកសារទស្សនៈទាន

# កម្មវិធីសិក្ខាសាលា

# ការផ្ទៀងផ្ទាត់ទិន្នន័យ និងប្រមូលធាតុចូលសម្រាប់ការសិក្សាស្រាវជ្រាវ

# ស្ដីពី

# "បរិយាកាសអំណោយផល និងភាពជាដៃគូប្រកបដោយបរិយាបន្នសម្រាប់អង្គការសង្គមស៊ីវិលកម្ពុជា"

## កាលបរិច្ឆេទៈថ្ងៃទី១៩ ខែ មិថុនា ឆ្នាំ២០២៦

ម៉ោង៖ ៨.៣០ ព្រឹក ដល់ម៉ោង ១២.០០ ថ្ងៃត្រង់

ទីកន្លែង៖ Anik Palace Hotel

អាសយដ្ឋាន៖ផ្ទះលេខ១១៤ ផ្លូវ២៧៨ សង្កាត់បឹងកេងកង១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ

ផែនទី៖https://maps.app.goo.gl/3kzCrTtg3KvjB9vM7

## ១.សាវតារ

អង្គការ គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គ.ស.ក.) គឺជាអង្គការសមាជិកភាពឈានមុខសម្រាប់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេសនៅក្នុងប្រទេសកម្ពុជា។ អង្គការ គ.ស.ក. មានសមាជិក២០០ អង្គការ ដែលធ្វើការងារអភិវឌ្ឍលើវិស័យផ្សេងៗ។ គ.ស.ក. បានដើរតួនាទីជាពិសេសក្នុងនាមជាអ្នកសម្របសម្រួល អ្នកឃ្លាំមើល និងអ្នកតស៊ូមតិ ដើម្បីបរិយាកាសអំណោយផល និងមជ្ឈមណ្ឌលធនធានប្រកបដោយនិរន្តរភាពសម្រាប់អង្គការសង្គមស៊ីវិលនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គ.ស.ក) បានប្រគល់ការងារជូន អង្គការវេទិកាអនាគត ជាទីប្រឹក្សាឯករាជ្យ ដើម្បីសិក្សាស្រាវជ្រាវលើប្រធានបទ "បរិយាកាសអំណោយផល និងភាពជាដៃគូប្រកបដោយបរិយាបន្នសម្រាប់អង្គការសង្គមស៊ីវិល " ។ ការសិក្សានេះមានគោលបំណងឆ្លុះបញ្ចាំងពីការអនុវត្តជាក់ស្តែងស្តីពីបរិយាកាសអំណោយផល និងភាពជាដៃគូប្រកបដោយបរិយាបន្នក្នុងចំណោមអង្គការសង្គមស៊ីវិល ព្រមទាំងរវាងអង្គការសង្គមស៊ីវិល រដ្ឋាភិបាល និងវិស័យឯកជន។

## ២. គោលបំណង៖

គោលបំណងនៃការសិក្សាស្រាវជ្រាវជាក់លាក់នេះរួមមាន ៖

- ដើម្បីវាយតម្លៃបរិយាកាសអំណោយផលសម្រាប់អង្គការសង្គមស៊ីវិលនៅគ្រប់ទិដ្ឋភាពសំខាន់ៗ យល់ដឹងអំពីតម្រូវការបច្ចុប្បន្នរបស់អង្គការសង្គមស៊ីវិល បង្កើតលំហកិច្ចសន្ទនាសម្រាប់អង្គការ

សង្គមស៊ីវិលជាមួយរដ្ឋាភិបាល និងផ្តល់អនុសាសន៍ជាក់លាក់ដើម្បីកែលម្អបរិយាកាសអំណោយផល និងភាពជាដៃគូប្រកបដោយបរិយាបន្នសម្រាប់អង្គការសង្គមស៊ីវិល។

- ពិនិត្យមើលយន្តការភាពជាដៃគូរួមបញ្ចូលដែលមានស្រាប់ តាមរយៈកិច្ចសហប្រតិបត្តិការអន្តរវិស័យ។ របកគំហើញស្រាវជ្រាវនេះ ជាមូលដ្ឋានក្នុងការទាញសេចក្តីសន្និដ្ឋាន និងផ្តល់អនុសាសន៍ ដើម្បីធ្វើឱ្យប្រសើរឡើងនូវបរិយាកាសអំណោយផល និងភាពជាដៃគូប្រកបដោយបរិយាបន្នសម្រាប់អង្គការសង្គមស៊ីវិលនៅកម្ពុជា។

**៣.សិក្ខាកាមៈ** កិច្ចពិភាក្សានេះរំពឹងថានឹងមានអ្នកចូលរួមមកពីអង្គការសមាជិក អង្គការដៃគូ តំណាងក្រសួង-ស្ថាប័ននៃរាជរដ្ឋាភិបាល ប្រមាណ ២០-២៥ នាក់ អញ្ជើញចូលរួម។

**៤.ក្រុមការងារសម្របសម្រួល**:

- អ្នកដឹកនាំពិភាក្សាៈ **លោក ជា ដារ៉ា** អ្នកស្រាវជ្រាវនៅអង្គការវេទិកាអនាគត (Future Forum Research Fellow)
- អ្នកកត់ត្រាៈ **កញ្ញា កុច ស្រីមាន** និង **លោក ម៉ឺន រិទ្ធី** អ្នកស្រាវជ្រាវនៅអង្គការវេទិកាអនាគត (Future Forum Junior Research Fellows)

**៥.របៀបវារៈ**

| **ពេលវេលា** | **សកម្មភាព** | **អ្នកសម្របសម្រួល** |
|---|---|---|
| ៨:៣០–៩:០០ | **ចុះឈ្មោះអ្នកចូលរួម និងកសាងបណ្តាញ** | ក្រុមការងារអង្គការ គ.ស.ក |
| ៩:០០–៩:០៥ | បង្ហាញអំពីកម្មវិធី និងការណែនាំក្រុមការងារ | ក្រុមការងារអង្គការ គ.ស.ក |
| ៩:០៥–៩:១៥ | មតិស្វាគមន៍ | ក្រុមការងារអង្គការ គ.ស.ក |
| ៩:១៥–១០:១៥ | បង្ហាញអំពីលទ្ធផលស្រាវជ្រាវ | ក្រុមការងារស្រាវជ្រាវនៃអង្គការវេទិកាអនាគត |
| **១០:១៥–១០:៣០** | **អាហារសម្រន់** | **អ្នកចូលរួមទាំងអស់គ្នា** |

| | | |
|---|---|---|
| ១០:៣០–១២:០០ | **សំណួរ&ចម្លើយ**<br>កិច្ចពិភាក្សាលើប្រធានបទស្រាវជ្រាវសំខាន់ៗៈ<br>• តើព័ត៌មាននេះត្រឹមត្រូវដែរឬទេ?<br>• តើអ្នកមានព័ត៌មានចង់បន្ថែមដែរឬទេ?<br>• តើមានព័ត៌មានណាមួយដែលបាត់ទេឬមិនបានដាក់បញ្ចូល?<br>• តើមានព័ត៌មានណាមួយដែលអ្នកចង់ផ្លាស់ប្តូរកែតម្រូវ និងបន្ថែមទេ? | ក្រុមការងារស្រាវជ្រាវនៃអង្គការវេទិកាអនាគត |
| **១២:០០** | **សម្រាកអាហារថ្ងៃត្រង់រួមគ្នា** | **អ្នកចូលរួមទាំងអស់គ្នា** |

សម្រាប់កិច្ចពិភាក្សាទាំងអស់ត្រូវបានអនុវត្តក្រោម គោលការណ៍ Chatham House Rule។ អត្តសញ្ញាណរបស់អ្នកចូលរួមនឹងត្រូវបានរក្សាទុកជាសម្ងាត់ ហើយរាល់មតិយោបល់នឹងមិនត្រូវបានបញ្ជាក់ជាបុគ្គល ឬ ស្ថាប័នណាមួយក្នុងរបាយការណ៍ចុងក្រោយឡើយ ដើម្បីធានាបាននូវការពិភាក្សាមួយដោយសេរី និងភាពបើកចំហ។

DRAFT



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street. 476,
Toul Tompoung 1, Chamkamorn
P.O. Box 885, Phnom Penh,
Cambodia